# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

# ស្តីពី

# កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ

# ឆ្នាំ២០១៣

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីទំនាក់ទំនងជាមិត្តភាពដែលមានកន្លងមករវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហ៍ពន្ធអាល្លឺម៉ង់ ក្នុងបំណងពង្រឹង និងរឹតទំនាក់ទំនងជាមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងស្មារតីភាពជាដៃគូ កិច្ចព្រមព្រៀងនេះ បង្កើតជាមូលដ្ឋានគ្រឹះនៃការថែរក្សាទំនាក់ទំនង
ក្នុងគោលបំណងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
យោងកំណត់ហេតុកិច្ចចរចាឆ្នាំ២០១៣ រវាងរដ្ឋាភិបាលទាំងពីរនៅទីក្រុង ភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣ និង អនុលោមតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០១២ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣

បានព្រមព្រៀងគ្នាដូចតទៅៈ

## មាត្រា ១

(១) រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបានពី "សាជីវកម្មឥណទាននីតិសម្បទាៈ (Reconstruction Loan Corporation – KfW)" នូវការផ្តល់វិភាគទានហិរញ្ញវត្ថុ ជាទឹកប្រាក់សរុប ២៣,000,000 អឺរ៉ូ (ម្ភៃបីលានអឺរ៉ូ) សម្រាប់គម្រោងដូចខាងក្រោមៈ

១- ការគាំពារសុខភាពសង្គម ដំណាក់កាលទី៤ (Social Health Protection IV) មានទឹកប្រាក់ដល់ត្រឹម ១២,000,000 អឺរ៉ូ (ដប់ពីរលានអឺរ៉ូ)

២- កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី៤ (Rural Infrastructure Programme IV) មានទឹកប្រាក់ដល់ត្រឹម ២.000.000 អឺរ៉ូ (ពីរលានអឺរ៉ូ) ។

៣- កម្មវិធីហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដើម្បីចីរភាពនៃកំណែទម្រង់ដីធ្លី (Economic Infrastructure Programme to Sustain Land Reform) មានទឹកប្រាក់ដល់ត្រឹម ៩.000.000 អឺរ៉ូ (ប្រាំបួនលានអឺរ៉ូ) ។

ប្រសិនបើការសិក្សាត្រូវបានរកឃើញថា គម្រោងទាំងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំរុញការអនុវត្ត ។

(២) គម្រោងដែលបានចែងដូចក្នុងកថាខ័ណ្ឌទី (១) ខាងលើ អាចនឹងត្រូវជំនួសដោយគម្រោងផ្សេងៗទៀត ប្រសិនបើ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា មានការឯកភាពគ្នា ។

(៣) កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តផងដែរនៅថ្ងៃក្រោយ ប្រសិនបើរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលកម្ពុជាទទួលបានវិភាគទានហិរញ្ញវត្ថុបន្ថែមពី KfW សម្រាប់ត្រៀមរៀបចំគម្រោងដែលមានចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬ សម្រាប់ចូលរួមចាត់វិធានការចាំបាច់ដើម្បីអនុវត្តនិងគាំទ្រគម្រោងដែលមានចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

## មាត្រា ២

(១) ការប្រើប្រាស់ចំនួនទឹកប្រាក់ដែលបានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ និងលក្ខខណ្ឌផ្តល់ជូន ក៏ដូចជានីតិវិធីសម្រាប់ផ្តល់កិច្ចសន្យា នឹងត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងនានាដែលចុះហត្ថលេខារវាង KfW និងអ្នកទទួលវិភាគទានហិរញ្ញវត្ថុ ដែលជាកម្មវត្ថុស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានា របស់សាធារណរដ្ឋ-សហព័ន្ធអាល្លឺម៉ង់ ។

(២) ការសន្យាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដែលមានចំនួនដូចបានបញ្ជាក់ក្នុងមាត្រា ១ (១) នៃកិច្ចព្រម-ព្រៀងនេះ នឹងអស់សុពលភាព ប្រសិនបើកិច្ចព្រមព្រៀងហិរញ្ញប្បទានពាក់ព័ន្ធនានា មិនបានចុះហត្ថលេខាក្នុងរយៈពេលប្រាំពីរឆ្នាំ ក្រោយឆ្នាំនៃការសន្យាបានធ្វើឡើង ។ ទឹកប្រាក់នៃការសន្យានេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ។

(៣) រាជរដ្ឋាភិបាលកម្ពុជាដែលមិនមែនជាអ្នកទទួលវិភាគទានហិរញ្ញវត្ថុនេះដោយផ្ទាល់ត្រូវធានាលើការសងប្រាក់ទាន់ពេលកំណត់ទៅអោយ KfW វិញ ផ្អែកតាមកិច្ចសន្យាហិរញ្ញប្បទាននានា ដែលនឹងត្រូវបានចុះហត្ថលេខាស្របតាមកថាខ័ណ្ឌ (១) ខាងលើ ។

## មាត្រា ៣

រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកក្នុងការបង់ពន្ធ អាករ និងថ្លៃសេវាសាធារណៈដទៃផ្សេងទៀត ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ជំនួសឱ្យ KfW ពាក់ព័ន្ធនឹងការសម្រេច និងការអនុវត្តកិច្ចសន្យានានាដោយផ្អែកតាមមាត្រា ២ (១) នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤

រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុញ្ញាតឱ្យអ្នកដំណើរ និងអ្នកផ្គត់ផ្គង់ ជ្រើសរើសសហគ្រាសដឹកជញ្ជូនដោយសេរី សម្រាប់ការដឹកជញ្ជូនមនុស្ស និងទំនិញ តាមសមុទ្រ និងតាមអាកាស ដែលស្តែងចេញពីការផ្តល់វិភាគទានហិរញ្ញវត្ថុខាងលើ ដោយជៀសវាងពីការដាក់វិធានការណាមួយដែលអាចរារាំងការចូលរួម ឬធ្វើអោយលំបាកដល់ការចូលរួមដោយស្មើភាពគ្នារបស់សហគ្រាសដឹកជញ្ជូនដែលមានទីតាំងធុរៈកិច្ចនៅក្នុង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងផ្តល់ការអនុញ្ញាតចាំបាច់ សម្រាប់ការចូលរួមរបស់សហគ្រាសទាំងនោះ ។

## មាត្រា ៥

(១) ទឹកប្រាក់ហិរញ្ញប្បទានចំនួន ៣,000,000 អឺរ៉ូ (បីលានអឺរ៉ូ) ដែលជាវិភាគទានហិរញ្ញវត្ថុសម្រាប់ប្រើប្រាស់ក្នុងគម្រោង " កម្មវិធីរៀបចំដែនដី និងគោលនយោបាយដីធ្លី " ដែលមានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពី កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ឆ្នាំ ២០១១ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២ នឹងត្រូវផ្ទេរទៅប្រើប្រាស់សម្រាប់គាំទ្រគម្រោង " កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី៤ " ប្រសិនបើការសិក្សាត្រូវបានរកឃើញថា គម្រោងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំរុញការអនុវត្ត ។ ការសន្យាផ្តល់ហិរញ្ញប្បទាននេះនឹងអស់សុពលភាព ប្រសិនបើកិច្ចព្រមព្រៀងហិរញ្ញប្បទានពាក់ព័ន្ធនានា មិនបានចុះហត្ថលេខាក្នុងរយៈពេលប្រាំបីឆ្នាំ ក្រោយឆ្នាំ២០១១ ដែលការសន្យាបានធ្វើឡើង ។ ទឹកប្រាក់នៃការសន្យា នេះមានសុពលភាពត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។

(២) ទឹកប្រាក់ហិរញ្ញប្បទានចំនួន ៦,000,000 អឺរ៉ូ (ប្រាំមួយលានអឺរ៉ូ) ដែលជាវិភាគទានហិរញ្ញវត្ថុដែលបានសន្យាផ្តល់កាលពីឆ្នាំ២០០៩ សម្រាប់ប្រើប្រាស់ក្នុងគម្រោង " កម្មវិធីរៀបចំដែនដី និងគោលនយោបាយដីធ្លី " ដែលមានចែងក្នុងមាត្រា ៥ (១) នៃកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពី កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ឆ្នាំ២០១១ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១២ នឹងត្រូវផ្ទេរទៅប្រើប្រាស់សម្រាប់គាំទ្រគម្រោង "កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី៤ " ប្រសិនបើការសិក្សាត្រូវបានរកឃើញថា គម្រោងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំរុញការអនុវត្ត ។ ការសន្យាផ្តល់ហិរញ្ញប្បទាននេះនឹងអស់សុពលភាព ប្រសិនបើកិច្ចព្រមព្រៀងហិរញ្ញប្បទានពាក់ព័ន្ធនានា មិនបានចុះហត្ថលេខាក្នុងរយៈពេលប្រាំបីឆ្នាំ ក្រោយឆ្នាំ២០០៩ ដែលការសន្យាបានធ្វើឡើង ។ ទឹកប្រាក់នៃការសន្យានេះមានសុពលភាពត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ ។

(៣) រាល់លក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ឆ្នាំ២០១១ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២ នឹងត្រូវអនុវត្តសម្រាប់គម្រោង " កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី៤ " នេះ ។

## មាត្រា ៦

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

យោងតាមមាត្រា១០២នៃធម្មនុញ្ញអង្គការសហប្រជាជាតិ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នឹងចុះបញ្ជីនៃកិច្ចព្រមព្រៀងនេះនៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ ភាគីហត្ថលេខីម្ខាងទៀត នឹងត្រូវបានផ្តល់ព័ត៌មានស្តីពីការចុះបញ្ជីនិងលេខបញ្ជីការរបស់អង្គការសហប្រជាជាតិ ឱ្យបានឆាប់បន្ទាប់ពីមានការបញ្ជាក់ពី លេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ មាន ២ ច្បាប់ដើម ចម្លងជាបីភាសាគឺ ភាសាខ្មែរ អាល្លឺម៉ង់ និង អង់គ្លេស អត្ថបទទាំង ៣ ភាសានេះមានតំលៃដូចគ្នា ។ ក្នុងករណីការបកប្រែមិនស្របមតិគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និង ខ្មែរ នោះអត្ថបទភាសាអង់គ្លេសនឹងត្រូវទុកជាបានការ ។

**តំណាង**
**រាជរដ្ឋាភិបាលកម្ពុជា**

**តំណាងរដ្ឋាភិបាល**
**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**